## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### កិច្ចព្រមព្រៀងការព្យួរកិច្ចសន្យាការងារ
### រវាងរោងចក្រ ស៊ីនចាង ថេកអ៊ីន និងតំណាងកម្មករ

ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៥:៣០នាទី នៅក្នុងបរិវេណនៃរោងចក្រស៊ីនចាង ថេក អ៊ីនដែលមានសមាសភាពចូលរួមមានដូចជា៖បុគ្គលិក កម្មករ តំណាងកម្មករ ប្រធានផ្នែក រដ្ឋបាល និងនាយកប្រចាំរោងចក្រស៊ីនចាង ថេក អ៊ីន។

**<u>បានព្រមព្រៀង និងឯកភាពចំនុចមួយចំនួនរួមមានដូចខាងក្រោម៖</u>**

**ចំនុចទី១** -ដោយសារការរាតត្បាតនៃជម្ងឺកូវីត ១៩បានធ្វើអោយពិភពលោកទាំងមូលមានផលរប៉ះពាល់យ៉ាងខ្លាំង ដែលជាហេតុធ្វើអោយសហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរជួបនូវបញ្ហាយ៉ាងធ្ងន់ធ្ងរ ព្រោះតែមិនមានការបញ្ជាទិញទំនិញបន្តទៀត។

**ចំនុចទី២** -ដោយរោងចក្រមិនមានការបញ្ជាទិញទំនិញ និងយោងទៅលើសេចក្តីណែនាំលេខ ០៤៥/២០ កប/ស.ណ.ន.ខ .ល ស្តីពីការព្យួរកិច្ចសន្យាការងារសម្រាប់រោងចក្រសហគ្រាស ចេញដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រោងចក្រស៊ីនចាង ថេក អ៊ីន បានសម្រេចធ្វើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១៩ នាក់ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៣៨នាក់ ដែលរយៈពេលនៃការព្យួរ ដោយគិតចាប់ពីថ្ងៃទី ១៥ ខែឧសភា រហូតដល់ថ្ងទី ១៥ ខែមិថុនា ឆ្នាំ ២០២០។

**ចំនុចទី៣** -រោងចក្រនិង ផ្តល់ប្រាក់ឧបត្ថម្ភចំនួន **៣០ដុល្លាអាមេរិក**សម្រាប់ការព្យួររយៈពេល២១ថ្ងៃដល់១ខែ។ហើយប្រាក់ចំនួន៣០ដុល្លាអាមេរិក រោងចក្រនិងធ្វើការបើកជូនបងប្អូនមុនថ្ងៃឈប់សម្រាកពេលព្យួរកិច្ចសន្យាការងារ។

-ទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល ចំនួន **៤០ដុល្លាអាមេរិក**សម្រាប់ការព្យួររយៈពេល ២១ថ្ងៃ ដល់១ខែ។

**ចំនុចទី៤** -ក្រោយពេលព្យួរកិច្ចសន្យាការងារចំនួន១០ថ្ងៃ កម្មករនិយោជិតនិងទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង ដែលជម្រាបដំណឹងអំពីចំនួនទឹកប្រាក់ដែលទទួលបាន។

**ចំនុចទី៥** -ក្រោយពេលទទួលបានសារជូនដំណឹងតាមទូរស័ព្ទ សូមបងប្អូនយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបាននោះ ទៅភ្នាក់ងារវីងណាមួយដែលនៅជិតផ្ទះ។ បើបងប្អូនខកខានមិនបានទៅបើកក្នុងរយៈពេល១០ថ្ងៃក្រោយពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង ថវិកានោះនិងបង្វិលជូនរាជរដ្ឋាភិបាលវិញ។

**ចំនុចទី៦** -សំរាប់បងប្អូនដែលបានឈប់សម្រាកដោយព្យួរកិច្ចសន្យាការងារ សូមចូលរួមទប់ស្កាត់ជំងឺកូវីដ ១៩ មិនត្រូវ

ទៅកន្លែងដែលមានមនុស្សច្រើន ត្រូវពាក់ម៉ាស់ និងលាងដៃជាប្រចាំ យើងអាចភ្លេចជំងឺកូវីដ ១៩បាន តែជំងឺកូវីដ១៩ មិនដែលភ្លេចយើងទេ សូមចូលរួមទប់ស្កាត់ទាំងអស់គ្នា។សូមអរគុណ!

ថ្ងៃព្រហស្បត្តិ៍ ០៩កើត ខែពិសាខ ឆ្នាំជូត ទោស័ក ពុទ្ធស័ករាជ ២៥៦

ភ្នំពេញ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០២០

**ស្នាមមេដៃភាគីតំណាងកម្មករ**

**ស្នាមមេដៃភាគីនិយោជក**